# មគ្គុទ្ទេសក៍ ចំពោះការបោះឆ្នោតសហព័ន្ធ




It's Our Vote

ទស្សនា elections.ca សំរាប់ព័ត៌មានជាផ្លូវការ ដែលអ្នកត្រូវការដើម្បីបោះឆ្នោត

1-800-463-6868 / elections.ca / TTY 1-800-361-8935

Elections Canada

# បញ្ជីពិនិត្យ សំរាប់អ្នកបោះឆ្នោត

**ធ្វើឲ្យប្រាកដ ថាអ្នកបានចុះឈ្មោះ**
នៅអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក

**ឃ្លាំមើលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត**
របស់អ្នក តាមប្រៃសណីយ៍

**ធ្វើគំរោងដើម្បីបោះឆ្នោត**

- នៅស្ថាននីយបោះឆ្នោតរបស់អ្នក បានចាត់តាំង **នៅថ្ងៃបោះឆ្នោត**
- នៅស្ថាននីយបោះឆ្នោតរបស់អ្នក បានចាត់តាំង **នៅថ្ងៃបោះឆ្នោតជាមុន**
- នៅ**ការិយាល័យបោះឆ្នោតកាណាដា** ណាមួយ ពាសពេញប្រទេសកាណាដា (កាលកំណត់អនុវត្ត)
- **តាមប្រៃសណីយ៍៖** ទស្សនា **elections.ca** ដើម្បីរកឲ្យដឹងថែមទៀត (កាលកំណត់អនុវត្ត)

រកឲ្យដឹងថា **អ្នកណាជាបេក្ខជន**
នៅក្នុងមណ្ឌលរបស់អ្នក

**យក ID មក** នៅពេលអ្នកទៅ
បោះឆ្នោត

---

ឃោសនាប័ណ្ណនេះ គឺមានជាច្រើនភាសានៅ **elections.ca**។
សំរាប់ទំរង់ផ្សេងទៀត ដូចជាអក្សរប្រ៊ៃល អក្សរពុម្ពធំៗ និង DAISY សូមទូរស័ព្ទមកយើង។

# មានការបោះឆ្នោតសហព័ន្ធ នៅឆ្នាំនេះ

## ធ្វើឲ្យប្រាកដ ថាអ្នកបានចុះឈ្មោះ ដើម្បីឲ្យបានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត




**បើសិនអ្នកបានចុះឈ្មោះ** អ្នកនឹងបានប័ណ្ណព័ត៌មានអ្នកបោះឆ្នោត តាមប្រៃសណីយ៍ បន្ទាប់ពីការបោះឆ្នោតត្រូវបានប្រកាស។ វាប្រាប់អ្នកអំពីទីកន្លែង និងពេលវេលាអ្នកអាចបោះឆ្នោតបាន។ ត្រូវយកប័ណ្ណនេះមកជាប់ខ្លួនអ្នក ព្រមទាំង ID ដែលអាចទទួលយកបានផង នៅពេលអ្នកទៅបោះឆ្នោត ដើម្បីធ្វើឲ្យដំណើរការបោះឆ្នោតងាយស្រួលជាង។

**បើសិនអ្នកមិនបានទទួលប័ណ្ណទេ ឬបើសិនព័ត៌មាននៅលើវាគឺខុស** អ្នកអាចនឹងមិនបានចុះឈ្មោះទេ ឬព័ត៌មានអ្នកបោះឆ្នោតរបស់អ្នក អាចនឹងមិនទាន់បច្ចុប្បន្នកាលឡើយ។ ទស្សនា **elections.ca** ឬទូរស័ព្ទមកយើង តាមលេខ **1-800-463-6868** ដើម្បីឆែកមើល និងកែការចុះឈ្មោះរបស់អ្នក។ អ្នកក៏អាចចុះឈ្មោះ នៅពេលអ្នកទៅបោះឆ្នោត បានដែរ។

---

## ដើម្បីចុះឈ្មោះ និងបោះឆ្នោត ក្នុងការបោះឆ្នោតសហព័ន្ធបាន អ្នកត្រូវតែ៖

- ជាសញ្ជាតិកាណាដា
- មានអាយុយ៉ាងតិចបំផុត 18 ឆ្នាំ នៅថ្ងៃបោះឆ្នោត
- បញ្ជាក់អត្តសញ្ញាណ និងអាសយដ្ឋានរបស់អ្នក

# មធ្យោបាយបោះឆ្នោត

**អ្នកអាចបោះឆ្នោតបាន ស្ទើរតែនៅពេលណាមួយ ក្នុងអំឡុងរយៈពេលបោះឆ្នោត។**
ជ្រើសរើសជំរើសការបោះឆ្នោត ដែលដំណើរការល្អប្រពៃសំរាប់អ្នក។

## 1 នៅថ្ងៃបោះឆ្នោត

ស្ថានីយបោះឆ្នោតរបស់អ្នក បានចាត់តាំង នឹងបើកចំនួន 12 ម៉ោង (ម៉ោងខុសៗគ្នា ទៅតាមខែត្រ)។

## 2 នៅថ្ងៃបោះឆ្នោតជាមុន

ស្ថានីយបោះឆ្នោតរបស់អ្នក បានចាត់តាំង នឹងបើក ពីម៉ោង 9:00 ព្រឹក ដល់ 9:00 យប់ នៅថ្ងៃសុក្រ ថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និងថ្ងៃច័ន្ទ នៃអាទិត្យមុនថ្ងៃបោះឆ្នោត។

## 3 នៅការិយាល័យបោះឆ្នោតកាណាដាណាមួយ ពាសពេញប្រទេសកាណាដា

ទៅការិយាល័យបោះឆ្នោតកាណាដាណាមួយ នៅមុនថ្ងៃអង្គារ មុនថ្ងៃបោះឆ្នោត ម៉ោង 6:00 ល្ងាច។ អ្នកនឹងបោះឆ្នោត ដោយប្រើ វិធីសន្លឹកឆ្នោតពិសេស។ បន្ទាប់ពីការបោះឆ្នោតត្រូវបានប្រកាស ទស្សនា **elections.ca** ឬទូរស័ព្ទ មកយើង ដើម្បីរកការិយាល័យ ស្ថិតនៅជិតអ្នក បំផុត។

## 4 តាមប្រៃសណីយ៍

ទស្សនា **elections.ca** ឬទូរស័ព្ទមកយើង ដើម្បីរកឲ្យដឹងថែមទៀត។ កាលកំណត់អនុវត្ត។

ឆែកមើល **ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត** របស់អ្នក សំរាប់ថ្ងៃបោះឆ្នោតរបស់អ្នក ទីកន្លែង និងម៉ោង។

# ID ដើម្បីបោះឆ្នោត

## អ្នកមានជំរើសបីយ៉ាង ដើម្បីបញ្ជាក់អំពីអត្តសញ្ញាណ និងអាសយដ្ឋានរបស់អ្នក។

### ជំរើសទី 1



**បង្ហាញ ID មួយ នៃណាមួយទាំងនេះ**

- លិខិតបើកបររបស់អ្នក
- ប័ណ្ណអ្វីផ្សេងទៀត ដែលបានចេញឲ្យដោយរដ្ឋាភិបាលកាណាដា (សហព័ន្ធ, ខេត្ត/អាណាខេត្ត ឬតំបន់) ដែលមានរូបថត ឈ្មោះ និងអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក

**ឬ**

### ជំរើសទី 2



+



**បង្ហាញ ID ពីរមុខ**

ទាំងពីរមុខត្រូវតែមានឈ្មោះរបស់អ្នក ហើយយ៉ាងហោចណាស់ មួយត្រូវតែមានអាសយដ្ឋានបច្ចុប្បន្នរបស់អ្នក។

**ឧទាហរណ៍៖**

- ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត និងរបាយការណ៍ធនាគារ
- វិក្កយប័ត្រទឹកភ្លើង និងប័ណ្ណ ID និស្សិត

**តើពុំមានវត្ថុទាំងនេះឬ? គ្មានបញ្ហាទេឡើយ!**

មាន ID ផ្សេងៗទៀត ដែលអាចទទួលយកបាន។
ឆែកមើលនៅ **elections.ca** សំរាប់បញ្ជីពេញលេញ

**ឬ**

### ជំរើសទី 3



+



**បើសិនអ្នកពុំមាន ID ទេ**

អ្នកនៅតែអាចបោះឆ្នោតបាន បើសិនអ្នកប្រកាសអត្តសញ្ញាណ និងអាសយដ្ឋានរបស់អ្នក ជាលាយលក្ខណ៍អក្សរ និងឲ្យជនណាម្នាក់ដែលស្គាល់អ្នក និងបានចាត់តាំង ទៅកន្លែងបោះឆ្នោតរបស់អ្នក ធានាថាស្គាល់អ្នក។

អ្នកធានា ត្រូវតែអាចបញ្ជាក់អត្តសញ្ញាណ និងអាសយដ្ឋានរបស់គេ។
មនុស្សអាចធានាបាន សំរាប់មនុស្សតែម្នាក់ប៉ុណ្ណោះ (លើកលែងតែស្ថាប័នថែទាំយូរអង្វែង)។

# លទ្ធភាពចេញចូល

**អ្នកមានសិទ្ធិបោះឆ្នោតទាំងអស់ គឺត្រូវបានចាត់តាំងទៅស្ថានីយបោះឆ្នោត សំរាប់ថ្ងៃបោះឆ្នោត និងថ្ងៃបោះឆ្នោតជាមុន។** បន្ទាប់ពីការបោះឆ្នោតត្រូវបានប្រកាស ត្រូវធ្វើឲ្យប្រាកដ ថាស្ថានីយបោះឆ្នោតរបស់អ្នក បានចាត់តាំង ស្របតាមសេចក្តីត្រូវការ នៃលទ្ធភាពចេញចូលរបស់អ្នក ដោយៈ

- ឆែកមើលប័ណ្ណព័ត៌មានអ្នកបោះឆ្នោត របស់អ្នក;
- បញ្ចូលរហស្សលិខប្រៃសណីយ៍របស់អ្នក ចូលទៅក្នុងប្រអប់សេវាព័ត៌មានអ្នកបោះឆ្នោត នៅ **elections.ca**; ឬ
- ទូរស័ព្ទមកយើង តាមលេខ **1-800-463-6868** ឬ **1-800-361-8935 (TTY)**។

បើសិនអ្នកមានកង្វល់ អំពីលទ្ធភាពចេញចូល នៅស្ថានីយបោះឆ្នោតរបស់អ្នក បានចាត់តាំង សូមទូរស័ព្ទមកយើង។

ដើម្បីស្នើសុំជំនួយការបោះឆ្នោតជាមុន រួមទាំងការបកប្រែភាសា និងភាសាសញ្ញា ទូរស័ព្ទទៅការិយាល័យបោះឆ្នោតកាណាដា នៅក្នុងមណ្ឌលរបស់អ្នក នៅមុនថ្ងៃអង្គារ មុនថ្ងៃបោះឆ្នោត ឲ្យទាន់ម៉ោង 6:00 ល្ងាច។

---

## ប្រដាប់ប្រដា ជំនួយការបោះឆ្នោត និងសេវា នៅថ្ងៃបោះឆ្នោតៈ

- **សន្លឹកឆ្នោតធំជាង** ដោយមានឈ្មោះបេក្ខជន **ជាអក្សរពុម្ពធំៗ**
- **កែវពង្រីក (4 ដង)**
- **អក្សរធំៗ** និង **អក្សរប្រ៊ៃលចុះរាយបេក្ខជន**
- **ខ្មៅដៃមានកញ្ចាប់កាន់ធំ**
- **ទំរង់បោះឆ្នោតនៃកាយវិញ្ញាណ និងអក្សរប្រ៊ៃល**
- **ជំនួយក្នុងការគូសសន្លឹកឆ្នោតរបស់អ្នក**

It's Our Vote